ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៦-០៥-០០៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងប្រកាសលេខ ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៦០៤-០៦២ប្រក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមស្មារតីអង្គប្រជុំនៃថ្នាក់ដឹកនាំនៃធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០០៧។

## សម្រេច

**ប្រការ ១.** បង្កើតគណៈកម្មការមួយមានឈ្មោះថា " គណៈកម្មការគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា " ដែលក្នុងប្រការជាបន្តបន្ទាប់ហៅថា **"គណៈកម្មការ"**។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.** គណៈកម្មការរួមមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ទេសាភិបាល | ប្រធាន |
| ២. ទេសាភិបាលរង | អនុប្រធាន |
| ៣. អគ្គលេខាធិការ | សមាជិក |
| ៤. អគ្គនាយក | សមាជិក |
| ៥. ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |
| ៦. ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | សមាជិក |
| ៧. ប្រធាននាយកដ្ឋានត្រួតពិនិត្យ | សមាជិក |
| ៨. ប្រធាននាយកដ្ឋានប្រតិបត្តិការ | សមាជិក |
| ៩. ប្រធាននាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា | សមាជិក។ |

**ប្រការ ៣.** គណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីអវត្តមានរបស់ប្រធាន ហើយអាចអញ្ជើញមន្ត្រីជំនាញផ្សេងទៀតឱ្យចូលរួមក្នុងការប្រជុំតាមការចាំបាច់។

**ប្រការ ៤.** ការប្រជុំរបស់គណៈកម្មការត្រូវធ្វើយ៉ាងហោចណាស់រៀងរាល់ពីរខែម្តង។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានគណៈកម្មការអាចកោះប្រជុំគណៈកម្មការនៅពេលណាក៏បាន។

**ប្រការ ៥.** គណៈកម្មការមានមុខងារ និងភារកិច្ចដូចខាងក្រោម ៖

១. កំណត់ ដឹកនាំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល

២. ដាក់ចុះនូវវិធានការចាំបាច់ សំដៅធ្វើឱ្យស្ថានភាពសាច់ប្រាក់ងាយស្រួលក្នុងទីផ្សាររូបិយវត្ថុ ស្របតាមគោលដៅនៃការរក្សាស្ថិរភាពថ្លៃ

៣. សម្របសម្រួលទៅតាមលទ្ធភាព ជាមួយសមាសធាតុផ្សេងៗនៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ពិសេសគោលនយោបាយសារពើពន្ធ សំដៅទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

៤. សម្របសម្រួលទំនាក់ទំនងរវាងគោលនយោបាយរូបិយវត្ថុ និងបទបញ្ញត្តិប្រុងប្រយ័ត្ននៃការត្រួតពិនិត្យធនាគារ

៥. ផ្សព្វផ្សាយគោលនយោបាយរូបិយវត្ថុ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ។



៤៥

**ប្រការ ៦.** គណៈកម្មការមានក្រុមការងារមួយជាជំនួយការ ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រង ទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ។ ក្រុមការងារមានសមាសភាព ដែលតែងតាំងដោយទេសាភិបាល និងមានមុខងារ ភារកិច្ចដូចខាងក្រោម :

១- រៀបចំ និងផ្តល់ជូនគណៈកម្មការនូវព័ត៌មាន ព្រមទាំងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាព និងនិន្នាការសេដ្ឋកិច្ច ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មការក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ វិធានការ ឬឧបករណ៍គោលនយោបាយរូបិយវត្ថុ

២- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មការ ។

**ប្រការ ៧.** កំណត់ហេតុអង្គប្រជុំគណៈកម្មការត្រូវរៀបចំឱ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ។

**ប្រការ ៨.** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ២ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន។

**ប្រការ ៩.** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០៨

**ទេសាភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល :**

- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"